**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

ំណុំរឿងរក្សាការពារ
ខ៦៣៤ ចុះថ្ងៃទី ២៤
 តុលា ឆ្នាំ ២០១៤
កាសម្រេច
ខ...3248......ទ
 ០ ក ចុះថ្ងៃទី ២៨ ខែ
លា ឆ្នាំ ២០១៤

# ដីកាសម្រេចរក្សាការពារ

## យើង ឃី ឆៃ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា៥៤១ មាត្រា និង ៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមៈ នស-រកម-០៧០៦-០២១ចុះថ្ងៃទី០៦ ខែកក្កដាឆ្នាំ ២០០៦ ។

-បានឃើញ សំណុំរឿងរក្សាការពារលេខៈ ៦៣៤ ចុះថ្ងៃទី ២៤ ខែ ១០ ឆ្នាំ២០១៤

-បានឃើញមាត្រា ៣៣៦ និងមាត្រា ៣៣៧ នៃច្បាប់ស្តីពីការងារ។

-បានឃើញពាក្យសុំចេញដីកាសម្រេចរក្សាការពារចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១៤ លោក មេធាវី ស្រ៊ី គីមយូ ។

-ម្ចាស់បំណុលៈ លោក ស្រ៊ី គីមយូ ជាមេធាវីតំណាងដោយអាណត្តិឲ្យក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី មានអាសយដ្ឋានស្ថិតនៅ ភូមិ ត្រពាំងពោធិ៍ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

-កូនបំណុលៈ កម្មករ-និយោជិតទាំងអស់នៃក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា ) ភីអិលស៊ី ។

**<u>កម្មវត្ថុនៃបណ្តឹងសុំ:</u>** សុំឲ្យតុលាការចេញដីកាសម្រេចរក្សាការពារ ដែលមានខ្លឹមសារបង្គាប់ឲ្យកម្មករ-និយោជិតទាំងអស់នៃក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី មានអាសយដ្ឋានស្ថិតនៅ ភូមិ ត្រពាំងពោធិ៍ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ រាជធានី ភ្នំពេញ ចូលធ្វើការក្នុងក្រុមហ៊ុនឲ្យទៀងទាត់តាមវេន (រៀងរាល់ថ្ងៃធ្វើការ) តាមក្រុម តាមតួនាទី និងភារៈកិច្ចរៀងៗខ្លួន ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី)ម៉ោង ហើយមិនត្រូវធ្វើសកម្មភាពរារាំង និងប្រើឧបករណ៍បំពងសំលេង ... ឬ ធុងបាស់បំពងសំលេងនាំឲ្យរំខានដល់កម្មករ-និយោជិតឯទៀត ឬហាមឃាត់ការដឹកទំនិញសម្ភារៈចេញ-ចូលរបស់ក្រុមហ៊ុនឡើយ ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី)ម៉ោង គិតចាប់ពី ពេលទទួលបានដំណឹងដីកាសម្រេចនេះ ។ កម្មករ-និយោជិតដែលមិនបានចូលទៅធ្វើការវិញ នៅពេលផុតកំណត់រយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង ហើយគ្មានហេតុផលត្រឹមត្រូវចាត់ទុកថាមានកំហុសធ្ងន់ ។

-បានឃើញ កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ ។

-បានឃើញ សេចក្តីបញ្ជាក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៥៧ / ១៤ កបអ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤ ។

ក្រោយពីបានពិនិត្យ ពិចារណាលើសំណុំរឿងចប់សព្វគ្រប់ហើយ

## សំអាងហេតុ

១-តាមពាក្យសុំចេញដីកាសម្រេចរក្សាការពារចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ របស់លោកមេធាវី ស្រ៊ី គីមយូ កាលពីថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០១៤ សហព័ន្ធសហជីពគាំទ្រកម្មករកម្ពុជាមានឈ្មោះ នួន នី ជាប្រធាន បានដឹកនាំកម្មករ-និយោជិត នៅក្នុងក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ធ្វើកូដកម្មខុសច្បាប់ ដោយមិនមានការជូនដំណឹងតាមនីតិវិធីនៃច្បាប់ការងារ( ក្នុងការទាមទារលក្ខខណ្ឌការងារមួយចំនួន) ហើយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ និងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានធ្វើការផ្សះផ្សាវិវាទការងាររួមរវាងក្រុមហ៊ុន និងតំណាងសហព័ន្ធសហជីព,តំណាងកម្មករ-និយោជិតបើមិនសះជានោះ និងបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីធ្វើការដោះស្រាយស្របតាមនីតិវិធីច្បាប់បន្តទៀត ។ ប៉ុន្តែក្រុមសហព័ន្ធសហជីពនៅតែបន្តដឹកនាំកម្មករ-និយោជិតធ្វើកូដកម្ម មិនតែប៉ុណ្ណោះពួកគេបានញុះញង់និងរារាំង កម្មករ-និយោជិតឯទៀតមិនឲ្យចូលធ្វើការដោយរំលោភទៅលើច្បាប់ និងនីតិវិធីច្បាប់ស្តីពីការងារ ។ ទង្វើទាំងនេះនាំឲ្យក្រុមហ៊ុន មានការខាតបង់ប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ។

២-តាមមាត្រា៣២៤ នៃច្បាប់ស្តីពីការងារ ការៈធ្វើកូដកម្មត្រូវជូនដំណឹងមុនរយៈពេលយ៉ាងតិច៧ថ្ងៃនៃថ្ងៃធ្វើការ ហើយត្រូវតែកល់ទុកនៅសហគ្រាសឬគ្រឹះស្ថានរបស់ខ្លួនព្រម ទាំងជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារផងដែរ ។

៣-កូដកម្មដែលធ្វើឡើងដោយកម្មករ-និយោជិតបំពើការងារនៅក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី កាលពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ គឺធ្វើខុសនឹងនីតិវិធីច្បាប់ការងារតាមបញ្ញាត្តិមាត្រា ៣៣៦ ដែលចាត់ទុកថាជាកូដកម្មខុសច្បាប់ ។

៤-តាមមាត្រា ៣៣៧ កថាខណ្ឌទី២ នៃច្បាប់ការងារតំរូវឲ្យកម្មករ-និយោជិតចូលធ្វើការវិញក្នុង រយៈពេល ៤៨ម៉ោង ហើយកម្មករ-និយោជិតដែលមិនបានចូលធ្វើការវិញនៅមុនកំណត់៤៨ម៉ោង ហើយគ្មានហេតុផលត្រឹមត្រូវចាត់ទុកថាជាកំហុសធ្ងន់ ។

៥-ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញសេចក្តីបញ្ជាលេខ: ០៥៧/១៤ កបអ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៤

បញ្ជា:

ក-ផ្អាកជាបន្ទាន់ការធ្វើកូដកម្មរបស់កម្មករ-និយោជិតនៃក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធី ។ កូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការងារវិញចាប់ពីព្រឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ តទៅតាមវេនរបស់ខ្លួន ។

ខ-និយោជកនិងកូដករនៃក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ត្រូវអនុវត្តតាមសេចក្តីបញ្ជានេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

៦-ការធ្វើកូដកម្មរបស់កម្មករ-និយោជិតខាងលើនេះ គឺមិនបានគោរពតាមនីតិវិធីនៃការធ្វើកូដកម្មតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជាដូចជាការជូនដំណឹងមុនដើម្បីអាចឲ្យនិយោជករកវិធីដោះស្រាយនិង

ការបានាសេវាអប្បបរមាដើម្បីឲ្យក្រុមហ៊ុនអាចបន្តដំណើរការបានប្រក្រតីផងដែរ ដូច្នេះការធ្វើកូដកម្មរបស់កម្មករ ខាងលើនេះ គឺខុសច្បាប់ ។

៧-ដើម្បីឲ្យក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី មានដំណើរការប្រក្រតីឡើងវិញ កំដូចជាផលប្រយោជន៍របស់កម្មករ-និយោជិតទាំងអស់ចាំបាច់តុលាការត្រូវសម្រេចតាមការស្នើសុំរបស់ក្រុមហ៊ុន ។

៨-ចំពោះប្រាក់ប្រដាប់ក្តី គប្បីជាបន្ទុករបស់ក្រុមហ៊ុន ដោយហេតុថាការដែលកម្មករ-និយោជិត ចូលបំរើការក្នុងក្រុមហ៊ុនជាធម្មតាវិញ គឺជាប្រយោជន៍របស់ក្រុមហ៊ុនផងដែរ ។

## <u>ហេតុដូច្នេះសម្រេច</u>

១-បង្គាប់ឲ្យកម្មករ-និយោជិតទាំងអស់នៃក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល(ខេមបូឌា)ភីអិលស៊ី មានអាសយដ្ឋានស្ថិតនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញចូលធ្វើការក្នុងក្រុមហ៊ុនឲ្យទៀងទាត់តាមវេន (រៀងរាល់ថ្ងៃធ្វើការ) តាមក្រុម តាមតួនាទី និងភារៈកិច្ចរៀងៗខ្លួន ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី)ម៉ោង ហើយមិនត្រូវធ្វើសកម្មភាពរារាំង និងប្រើឧបករណ៍សំឡេង ឬ ធុងបាស់បំពងសំលេង នាំឲ្យរំខានដល់កម្មករ-និយោជិតឯទៀត ឬហាមឃាត់ការដឹកទំនិញសម្ភារៈចេញ-ចូលរបស់ក្រុមហ៊ុនឡើយ ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី)ម៉ោង គិតចាប់ពីពេលទទួលបានដំណឹងដីកាសម្រេចនេះ។

កម្មករ-និយោជិតដែលមិនបានចូលទៅធ្វើការវិញនៅពេលផុតកំណត់រយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង ហើយគ្មានហេតុផលត្រឹមត្រូវចាត់ទុកថាមានកំហុសធ្ងន់ ។

២-ប្រាក់ប្រដាក់ក្តីជាបន្ទុករបស់ក្រុមហ៊ុន ។

៣-ដីកាសម្រេចនេះមានអនុភាពអនុវត្តន៍ភ្លាម ។

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤

**ចៅក្រម**

ហត្ថលេខា និងត្រា **ឃី តែ**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**

ភន_សុវណ្ណឫទ្ធិ

បានឃើញ

**ចៅក្រម**

ឃី_ទ៉ែរ